# ជីវប្រវត្តិសង្ខេប
# របស់ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ អធិបតីពុទ្ធមណ្ឌល
# និងជាអគ្គនាយកវិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជា

ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** ប្រសូត្រនៅថ្ងៃ ច័ន្ទ ៣រោច ខែផល្គុណ ឆ្នាំវក អដ្ឋស័ក ព.ស ២៤៩៩ ត្រូវនឹង ថ្ងៃទី ១៨ ខែមិនា ឆ្នាំ ១៩៥៧ វេលាម៉ោង១២យប់ នៅភូមិរកាកោង ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ក្នុងត្រកូលកសិករ។ ញោមប្រុសនាម **ពុយ សំ** បានធ្វើមរណៈកាលពីឆ្នាំ ១៩៩៣ ។ ញោមប្រុសជាសីលវន្ត សមាទានអតិរេកសីល (សីល ១០) រហូតដល់អស់អាយុជីវិត ។ ញោមស្រីនាម **កែវ ស៊ុម** អាយុ ៧៩ឆ្នាំ ជាសីលវតី រក្សាសីល ១០ បច្ចុប្បន្នបដិបត្តិធម៌វិបស្សនាធុរៈនៅវត្ត **រកាកោង** ស្រុកមុខកំពូល ខេត្តកណ្តាល ។ ព្រះអង្គមាន បងប្អូនបង្កើត ៤ នាក់ :

ទី១- ឧបាសិកា **សំ គង់**

ទី២- លោក **សំ ឈឿន** (ស្លាប់)

ទី៣-ព្រះតេជគុណ **សំ ប៊ុនធឿន**

ទី៤- អ្នកស្រី **សំ ចេក**

## ១-អំពីកុមារភាព

កាលពីកុមារដោយមានលក្ខណៈសម្បត្តិមកពីធម្មជាតិ គួបផ្សំនឹងការអប់រំពីសំណាក់មាតា បិតា ផងនោះ កុមារ **សំ ប៊ុធឿន** គឺជាកុមារមួយរូបដែលមានអត្តចរិក និង អាកប្បកិរិយាថ្លៃថ្នូរ ទន់ភ្លន់ សុភាពរាបសារ និង ចេះជួយទុក្ខធុរៈអ្នកដទៃ ចេះគោរពឪពុកម្តាយ ចាស់ព្រឹទ្ធាចារ្យ គួរជាទីស្រឡាញ់រាប់អាន ។

លុះមានវ័យល្មមសិក្សា មាតាបិតាបានបញ្ជូនឱ្យទៅសិក្សារៀនសូត្រ លេខនព្វន្ត អក្សរសាស្ត្រ នៅសាលាបឋមសិក្សា វត្តតាំងគោក ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដែលជាទឹកដីកំណើតរបស់លោកឪពុក ។ លុះអាយុ ៨ ឆ្នាំ កុមារ **សំ ប៊ុនធឿន** បានមកសិក្សានៅសាលាបឋមសិក្សា រកាកោងក្រៅ ស្រុកមុខកំពូល ខេត្តកណ្តាល ខាងទឹកដីកំណើតរបស់អ្នកម្តាយវិញ រហូតដល់ថ្នាក់ទី ៧ ។ នៅអាយុ១៣ឆ្នាំបានប្រលងជាប់ចូលរៀននៅអនុវិទ្យាល័យ សេរីមង្គល នៅឃុំ រកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល។

លុះអាយុ ១៦ ឆ្នាំ យុវជន **សំ ប៊ុនធឿន**បានបន្តការសិក្សានៅវិទ្យាល័យ **ពៅ អ៊ុម** ដល់ថ្នាក់ទី ៣ រហូតដល់ព្រឹត្តិការណ៍ ១៧ មេសា ឆ្នាំ ១៩៧៥ ។

អាយុ ១៩ ឆ្នាំ នៅក្នុងរបប ៣ ឆ្នាំ ៨ខែ ២០ថ្ងៃ នៃបនប្រល័យពូជសាសន៍ យុវជន **សំ ប៊ុនធឿន** ត្រូវបានជន្លៀសចេញពីទីក្រុងភ្នំពេញ ដូចប្រជាជនទូទៅដែរ ។ នៅថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ ទើបត្រឡប់មករស់នៅស្រុកកំណើត ហើយបានជួបជុំឪពុកម្តាយ បងប្អូនវិញ។ បន្ទាប់ ពីបានជួបជុំលោកឪពុកម្តាយបង ប្អូនមក ដោយការតាំងចិត្តថា នឹងចូលសាងព្រះផ្នួស បំរើព្រះពុទ្ធសាសនារហូតអស់មួយជីវិត ដោយមិនគិតសាងជីវិតអាពាហ៍ពិពាហ៍ឡើយ ។

## ២~ អំពីជីវិតផ្នួស និងប្រវត្តិនៃការសិក្សា :

ដោយមានសទ្ធាជាញាណសម្បយុត្ត និង សុឆន្ទៈចំពោះព្រះពុទ្ធសាសនាស្រាប់ផងនោះ ទើបនៅឆ្នាំ ១៩៨០ យុវជន **សំ ប៊ុនធឿន** មានអាយុ ២៤ ឆ្នាំ ក៏បានចូលសាងព្រះផ្នួស បួសជាសាមណេរនៅក្នុងពុទ្ធសីមាវត្តកែវមុណីជោត ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម **គាំ ពេញ** ។

នៅឆ្នាំ ១៩៨១ ព្រះជន្ម ២៤ វស្សា បានបំពេញឧបសម្បទា ជាភិក្ខុភាវៈ នៅពុទ្ធសីមាវត្ត **ឃោសិតារាម** នៅឃុំស្តៅ ស្រុកកងមាស ខេត្តកំពង់ចាម ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ព្រះនាម **គង់ ណែម** និង ព្រះឧបសម្បទាចារ្យ ព្រះនាម **ជួន សំអិន** ហើយព្រះឧបជ្ឈាយ៍ឱ្យបព្វជិតនាមថា **គេតុធម្មោ** ។ បន្ទាប់ពីបំពេញឧបសម្បទាមកព្រះភិក្ខុ **សំ ប៊ុនធឿន** បានបំពេញការព្យាយាមក្នុងការសិក្សាកាន់តែទ្វេថែមទៀត មិនដែលតំអក់ទំរន់ម្តងណាឡើយ ដោយស្របទៅ តាមពាក្យចាស់ថា " **បួសរៀន** " ។ ហេតុនេះហើយ ទើបព្រះអង្គបានមកគង់នៅវត្ត **ក្តីចាស់ (សុរិយាពោធិមាស )** ស្រុក មុខកំពូល ខេត្តកណ្តាល ដើម្បីសិក្សាធម្មវិន័យក្នុងសំណាក់លោកអាចារ្យ **មាស ឈិន** រហូតចប់ថ្នាក់ត្រី និង ទោ ហើយអាចសម្តែងធម្មទេសនាបានពិរោះក្បោះក្បាយ ជាហេតុធ្វើឱ្យពុទ្ធបរិស័ទមានការចូលចិត្តគោរពរាប់អានច្រើន ។

លុះឆ្នាំ ១៩៨៣ ដល់ ១៩៨៥ ព្រះអង្គបានមកគង់នៅវត្ត **ពាមមង្គល** ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាលវិញ។ វស្សានោះ ព្រះអង្គបានអញ្ជើញលោកគ្រូធម្មាចារ្យ **មាស ឈិន** ដដែល មកបង្រៀនបញ្ចប់ធម្មវិន័យថ្នាក់ឯកជាបន្តទៀត។ ដោយវិរិយភាព និងព្រះទ័យរជះថ្លាចំពោះការសិក្សា ព្រះអង្គបានបញ្ចប់ធម្មវិន័យថ្នាក់ឯកដោយបរិបូរណ៍ ព្រមទាំងចេះចាំព្រះ អភិធម្មទាំង ៧គម្ពីរទាំងអត្ថ ទាំងព្យញ្ជនៈ ហើយមានសមត្ថភាព និងទេពកោសល្យកាន់តែចាស់ក្លាថែមទៀត ក្នុងការសម្តែង ធម្មទេសនាគ្រប់ទិសទី ។

លុះវស្សាទី ៧ ព្រះអង្គបានជួបផ្ទាល់ជាមួយធម្មាចារ្យនាម **រស់ ឈុន** ជាឧបាសកម្នាក់នៅបង្រៀនធមិវិបស្សនាក្នុងវត្ត **ពាមមង្គល** អាចចេះចាំផ្នែកវិបស្សនាធុរៈបានល្អប្រពៃ។ ពុទ្ធបរិស័ទវត្ត **ពាមមង្គល** គោរពបូជាធម្មាចារ្យជាគ្រូដ៏ប្រពៃ ក្នុងជំនាន់នោះ ។ ព្រះអង្គបានសិក្សា សមថ និង វិបស្សនាកម្មដ្ឋាន ជាមួយលោកតាគ្រូ **រស់ ឈុន** រហូតដល់ចប់កម្មដ្ឋានទាំង ៤០ ព្រមទាំងឈានសមាបត្តិដោយបរិបូរណ៍ក្នុងរយៈពេលតែ៧ឆ្នាំគត់ ។

ដោយសមត្ថភាពរបស់ព្រះអង្គកាន់តែចាស់ក្លា និងដោយការខ្វះខាតធម្មាចារ្យផងនោះ ទើបពុទ្ធបរិស័ទមានឧទ្ទេសាចារ្យ **អ៊ុន សារុន** ជាដើម និមន្តព្រះភិក្ខុ **សំ ប៊ុនធឿន** ឱ្យធ្វើ ជាព្រះធម្មាចារ្យបង្រៀនព្រះកម្មដ្ឋានដល់ភិក្ខុ សាមណេរ យាយ តា បន្ត ពីលោកតា **រស់ ឈុន** តទៅ ។

រៀងរាល់ល្ងាច នៅតូបតូចរបស់ព្រះអង្គ មានពន្លឺភ្លើងចង្កៀងផ្លុង១នាកណ្តាលរាត្រីពេលនោះហើយដែលព្រះអង្គកំពុងតែ ទន្ទេញមូលវេយ្យាករណ៍ភាសាបាលីរបស់លោកគ្រូ **ឈឹម ស៊ុម** ទាំង៧និទ្ទេស ចាំមាត់អស់រយៈកាលត្រឹមតែ ៣ខែប៉ុណ្ណោះ ។ ព្រះអង្គតែងតែសូត្រនូវមូលវេយ្យាករណ៍ ៧និទ្ទេសខាងលើនោះចាំរត់មាត់ដូចជា ធម៌សូត្រធម្មតារាល់ថ្ងៃឥតមានការភ្លេចភ្លាំងឡើយ ។ បន្ទាប់មកទៀតព្រះអង្គក៏រៀនសម្ពន្ធមាលា របស់លោកគ្រូ **អ៊ុក ខាំ** ចប់ទៀត ហើយអាចសម្ពន្ធបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍បាលីឥតមានទាស់ខុសឡើយ ។

លុះដល់ឆ្នាំទី២ ព្រះអង្គបានប្រែគម្ពីរធម្មបទចប់បាន ៤ភាគ ហើយយករឿងព្រមទាំងសាច់ធម៌សំដែងជូនយាយ តារាល់ថ្ងៃឧបោសថសីលទៀតផង ។

ឆ្នាំទី៣ (១៩៩៤) បានប្រែគម្ពីរធម្មបទភាគ ៥ ដល់ភាគ ៨ ចប់ដោយបរិបូរណ៍ ទាំងអត្ថនិងព្យញ្ជនៈមិនទើសទាល់ ។ មិនតែប៉ុណ្ណោះ ព្រះអង្គអាចសន្ទនាភាសាបាលីជាមួយប្រទេសដែលនិយាយភាសាបាលីបានខ្លះផង ។

ដោយខ្វះមធ្យោបាយ និងបង្រៀនគម្ពីរធំៗប្រគេនព្រះអង្គបន្តទៀតបាន ដូចជា **មង្គលត្ថទីបនី វិសុទ្ធមគ្គ** និង គម្ពីរផ្សេងៗទៀតនោះ ទើបឧទ្ទេសាចារ្យ **អ៊ុម សារុន** ក៏សម្រេចបវារណាព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ឱ្យព្រះអង្គនិមន្តទៅបន្តការសិក្សាព្រះបរិយត្តិធម៌ថ្នាក់មធ្យម ជាមួយលោកគ្រូឧទ្ទេសាចារ្យនាម **ជឹម ឡូញ** ហៅ **ថន** នៅវត្ត **សុវណ្ណវតី** ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ជាបន្តទៀតផង បង្រៀនវិបស្សនាធុរៈផង ។

លុះកន្លងមកចំនួនបីខែ (ដើមឆ្នាំ ១៩៩៦ ) ចប់ការបង្រៀននៅវត្ត សុវណ្ណវតីផង ព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ក៏ត្រូវនិមន្តទៅគង់នៅក្រុងភ្នំពេញនាវត្ត **នន្ទមុនី** សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យរាជធានីភ្នំពេញ ។

បន្ទាប់ពីមកគង់នៅទីនេះ ព្រះអង្គពុំសូវមានពេលទំនេរទេ មួយថ្ងៃៗ មានការងារជាច្រើន ដែលត្រូវបំពេញដូចជា ការរៀបចំផ្សព្វផ្សាយព្រះធម៌ តាមរយៈការចងក្រង និងនិពន្ធសៀវភៅ ការសំដែងធម៌ និងការរៀបចំគ្រប់គ្រងនៅទីនេះជាដើម ។ល។ និង ។ល។ ទោះជាការងារមានទំហំដ៏ធំធេងយ៉ាងណាក៏ដោយ ក៏ព្រះអង្គពុំដែលមានការត្អូញត្អែរម្តងណាឡើយ ។ មួយវិញទៀត ព្រះអង្គគឺជាព្រះសង្ឃមួយអង្គ ដែលមាន

វិរិយភាពខ្លាំងក្លាបំផុត ចំពោះវិស័យអប់រំ ជាពិសេសគឺការរៀនសូត្រផ្ទាល់ ព្រះអង្គនេះតែម្តង ។ ដូច្នេះហើយ បានជានៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០០ ព្រះអង្គបានបន្តការសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ជាបន្តទៀត ។ ក្នុងការសិក្សានៅពុទ្ធិកសាកលវិទ្យាល័យនេះ មានមុខវិជ្ជាជាច្រើនដែលត្រូវរៀនសូត្រដូចជា សង្គមវិទ្យា (Sociology) ច្បាប់ (law) នរវិទ្យា (Anthropology) វិទ្យាសាស្ត្រអប់រំ (Educational Science) តក្កវិទ្យា (Logic and Critical Thinking) និង ទស្សនៈវិទ្យា (Philosophy) ជាដើម តែមុខវិជ្ជាដែលព្រះអង្គពេញចិត្តនោះគឺ ទស្សនៈវិទ្យាព្រះពុទ្ធសាសនា (Buddhist philosophy) ។

ព្រះអង្គបានទទួលបរិញ្ញាប័ត្រផ្នែកទស្សនៈវិទ្យាព្រះពុទ្ធសាសនានៅឆ្នាំដែលព្រះអង្គអនិច្ចធម្ម ។

## ៣-សមិទ្ធិផលនានាដែលព្រះអង្គដឹកនាំកសាង

ទន្ទឹមនឹងការងាររៀនសូត្រ និងការអប់រំបង្រៀនធម៌ដល់ពុទ្ធបរិស័ទព្រះអង្គបានដឹកនាំកសាងនូវថាវរៈវត្ថុផ្សេងៗ ដើម្បីទុកជាប្រយោជន៍សំរាប់ជាតិ និង សាសនា បន្តទៀត ។ ដូច្នេះ សមិទ្ធិផលទាំងឡាយ ដែលព្រះអង្គបានកសាងមានដូចតទៅនេះ :

-នៅវត្ត **ពាមមង្គល** : បានក្រាលការ៉ូ កសាងបល្ល័ង្គ និង កសាងព្រះពុទ្ធបដិមា ថែមទាំងដឹកនាំកសាងសាលាបឋមសិក្សារកាកោងក្រៅ បាន៣ខ្នង ព្រមទាំងតុ កៅអី ផ្តើមកសាងនៅឆ្នាំ ១៩៨៣ ។

-នៅវត្ត **សុវណ្ណវតី** : បានកសាងស្រះទឹក កុដិថ្ម ព្រមទាំងរៀបរយផ្ទៃដីបានល្អប្រសើរទៀតផង ។

-នៅវត្ត **នន្ទមុនី** : ព្រះអង្គបានកសាងសមិទ្ធិផលដូចតទៅ :

១-សាងសង់ខឿនព្រះវិហារ

២-កុដិឈើមួយខ្នង

៣-អាគារថែវពីរខ្នង មានដប់បន្ទប់

៤-អាគារសិក្សាពីរខ្នង

៥-អាគារសមាធិមួយជាន់

៦-អាងទឹក ៦0$M^3$ x ២0$M^3$

-នៅ **ពុទ្ធមណ្ឌលវិបស្សនាធុរៈ** បានស្ថាបនាសមិទ្ធិផលដូចតទៅ :

១-ជីកស្រះ ចំនួន ៣

២-ព្រះវិហារ ( បាន ៨០ ភាគរយហើយ )

៣-ធម្មសភា បានរួចរាល់ជាស្ថាពរ ផ្តើមកសាងពីឆ្នាំ ១៩៩៩

៤-ម៉ាស៊ីនភ្លើងមួយគ្រឿងដែលមានកំឡាំង ៥០ គីឡូវ៉ាត់ ជាវនៅឆ្នាំ ១៩៩៩

៥-ផ្ទះបាយ និង ឃ្លាំងសំភារៈ រួចរាល់ជាស្ថាពរ ផ្តើមកសាងនៅឆ្នាំ ២០០០

៦-ពង្រីកផ្ទៃដីពុទ្ធមណ្ឌល ពី៦ហិចតា ដល់១៥ហិចតា ឆ្នាំ១៩៩៦-២០០០

៧-ចាក់ដីបំពេញរណ្តៅកុង ៤ហិចតាកន្លះ ឆ្នាំ១៩៩៨-២០០០

៨-មហាកុដិពីរជាន់ ផ្តើមកសាងពីឆ្នាំ ២០០០

៩-សាលាឆាន់បានរួចរាល់ជាស្ថាពរ ផ្តើមកសាងពីឆ្នាំ២០០០

១០-កុដិថ្មមួយខ្នងមានពីរជាន់ ៤បន្ទប់ ដោយថវិការរបស់ព្រះអង្គផ្ទាល់

១១-តូបស្លឹក ៣៥០ខ្នង ផ្តើមកសាងពីឆ្នាំ ២០០០-២០០១

១២-ផ្លូវថ្នល់ក្នុង និង ក្រៅពុទ្ធមណ្ឌល ផ្តើមកសាង ២០០០-២០០១

១៣-អាងទឹកចំណុះ ១០០០ម៉ែត្រគូប និង ៥០០ ម៉ែត្រគូប ព្រមទាំងបណ្តាញទឹកភ្លើង កសាងនៅឆ្នាំ ២០០២ ។

១៤-ក្លោងទ្វារអង្គរធំ-បន្ទាយស្រី កសាងនៅឆ្នាំ ២០០០-២០០១

១៥-បន្ទប់អនាម័យ២០ខ្នង (ក្នុង១ខ្នងមាន៥បន្ទប់) កសាងនៅឆ្នាំ ២០០១

១៦-ដងទង់ ១ គូ កសាងនៅឆ្នាំ ២០០១

១៧-ព្រះពុទ្ធបដិមាមុជ្ជលិន កសាងនៅឆ្នាំ ១៩៩៩-២០០០

១៨-បណ្ណាល័យ កសាងនៅឆ្នាំ ២០០២

១៩-សាលាអប់រំ កសាងនៅឆ្នាំ ២០០២

២០-កុដិព្រះសង្ឃ ១០០បន្ទប់ កសាងនៅឆ្នាំ ២០០២ (កំពុងសាងសង់)

២១-អាគារដាក់ម៉ាស៊ីនភ្លើងធំ-២៥០គីឡូវ៉ាត់

២២-សាលាវិបស្សនាសីលវ័ន្ត និងសីលវតី កសាងនៅឆ្នាំ ២០០២រហូត មកដល់បច្ចុប្បន្នមិនទាន់រួចរាល់នៅឡើយ ។

## ៤-ការងារបណ្តុះបណ្តាល និង អប់រំ

ដើម្បីបណ្តុះបណ្តាលសិស្ស និងអប់រំឱ្យបានទទួលនូវគុណភាពខ្ពស់ និងលទ្ធផលល្អនោះ ព្រះអង្គបានរៀបចំនូវគោលការណ៍ ដូចខាងក្រោម :

**ក-ការចងក្រង និង និពន្ធសៀវភៅ**

ព្រះអង្គបានរៀបរៀង និង ចងក្រងសៀវភៅ ហើយផ្សព្វផ្សាយជូនពុទ្ធបរិស័ទសំរាប់សិក្សាដូច ខាងក្រោម :

១-សមថ និង វិបស្សនាកម្មដ្ឋាន

២-សីលកថា សង្ខេប

៣-គោលធម៌ ថ្នាក់បឋម

៤-គោលធម៌ ថ្នាក់មធ្យម

៥-គោលធម៌ ថ្នាក់ឧត្តម

៦-បឋមវិបស្សនា ពិស្តារ

៧-គិរីមានន្ទសូត្រ

៨-បាដិហារិយ៍ុបោសថ

៩-និយមសីល

១០-វិក្រិត្យការគរុកោសល្យ

១១-មនុស្សចង់បានអ្វី

១២-ធុតង្គ និង បរិវាស

១៣-មធ្យមវិបស្សនា ពិស្តារ

១៤-វិន័យសីល ១០

១៥-ឧត្តមវិបស្សនា ឆ្នាំទី១ + ទី២ព្រះអង្គបានរៀបរៀងចប់ហើយ ប៉ុន្តែមិនទាន់បោះពុម្ពនៅឡើយ ។

**ខ-ការងារបណ្តុះបណ្តាល**

ដើម្បីតម្រូវទៅតាមសេចក្តីត្រូវការរបស់ពុទ្ធបរិស័ទទូទាំងប្រទេស ដែលខ្វះខាតនូវគ្រូកម្មដ្ឋាននោះ ព្រះអង្គបានបណ្តុះបណ្តាលនូវគ្រូបង្គោល និងសិក្ខាកាមដែលបានទទួលវិញ្ញាបនប័ត្រ មានចំនួន ២៤១០នាក់ ក្នុងនោះមាន :

ថ្នាក់ឧត្តមបានចំនួន.............១១រូប

ថ្នាក់មធ្យមបានចំនួន............៦១រូប

ថ្នាក់បឋមបានចំនួន......២៣៣៨រូប ។

**គ-ការបង្កើតមជ្ឈមណ្ឌលវិបស្សនាធុរៈតាមបណ្តាខេត្ត និង ការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងតាមលំដាប់ថ្នាក់មានដូចជា :**

១-មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត ក្រចេះ ( ថ្ងៃ២៦-០១ -៩៩ )

២- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្តតាកែវ ( ថ្ងៃ១០-០២-៩៩ )

៣- មជ្ឈមណ្ឌលវិបស្សនាធុរៈ ក្រុងកែប ( ថ្ងៃ១៨-០២-៩៩ )

៤- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត សៀមរាប ( ថ្ងៃ២៣-០៧-៩៩ )

៥- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្តពោធិ៍សាត់ ( ថ្ងៃ២០-០៥-២០០០ )

៦- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត កំពង់ធំ ( ថ្ងៃ៣១-០៨-២០០០ )

៧- មជ្ឈមណ្ឌលវិបស្សនាធុរៈ ក្រុងព្រះសីហនុ ( ថ្ងៃ០៩-០៩-២០០០ )

៨- មជ្ឈមណ្ឌលវិបស្សនាធុរៈ រាជធានីភ្នំពេញ ( ថ្ងៃ២២-១០-២០០០ )

៩- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត កំពង់ឆ្នាំង ( ថ្ងៃ០២-១១-២០០០ )

១០- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត ស្វាយរៀង ( ថ្ងៃ២៨-១១-២០០១ )

១១- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត កំពត ( ថ្ងៃ៣០-០៣-២០០២ )

១២- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត ព្រៃវែង ( ថ្ងៃ២៤-០៦-២០០២ )

១៣- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត មណ្ឌលគីរី ( ថ្ងៃ១៥-១២-២០០២ )

១៤- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត បន្ទាយមានជ័យ ( ឆ្នាំ ២០០៥ ) និង បង្កើតមណ្ឌលវិបស្សនាតាមស្រុក និង វត្ត បានចំនួន ៦៣ កន្លែងថែមទៀតដូចជា :

- វត្តទួលអង្កាញ់ ឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្ដាល
- វត្ត ប្រាសាទ ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប
- វត្ត កោះប៊ុនលី ឃុំ ពត់ស ស្រុក បាទី ខេត្តតាកែវ
- វត្ត ទួលទ្រា ឃុំ ជុប ស្រុក ត្បូងឃ្មុំ ខេត្តកំពង់ចាម
- វត្ត បន្ទាយជ័យ ឃុំ ស្ពឺ ស្រុក ចំការលើ ខេត្តកំពង់ចាម
- វត្ត សោមនស្ស ឃុំ ពាមឯក ស្រុក ឯកភ្នំ ខេត្តបាត់ដំបង
- វត្ត ពោធិ៍សិរីវង្ស ឃុំ បឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់
- វត្ត ព្រះស្រែ ឃុំកញ្ជ្រៀច ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង
- វត្ត ត្រពាំងធមិ ឃុំ កំពង់ត្រឡាច ស្រុក កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំ
- វត្ត ពោធិ៍រង្សី ឃុំ បាបោង ស្រុក ពាមរក៍ ខេត្តព្រៃវែង
- វត្ត បឹង ឃុំ សេដ្ឋី ស្រុក សាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

- វត្ត បន្ទាយត្រាវ ឃុំ កណ្ដឹង ស្រុក បាទី ខេត្តតាកែវ
- វត្ត សុវណ្ណបុប្ផារាម ឃុំ ក្អឿងរាយ ស្រុក កញ្ជ្រៀច ខេត្តព្រៃវែង
- វត្ត កងត្រណឹង ឃុំ កងត្រណឹង ស្រុក កងមាស ខេត្តកំពង់ចាម
- វត្ត ធនសិរី ឃុំ បរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ
- វត្ត ឧត្តមមុនីរតនារាម ឃុំថ្មពូន ស្រុកព្រៃឈរ ខេត្តកំពង់ចាម
- វត្ត ភ្នំរាប ឃុំពន្សាំង ស្រុកអង្គស្នួល ខេត្តកណ្ដាល
- វត្ត ភ្នំសមាធិ ឃុំ រាម ស្រុកព្រៃនប់ ខេត្តកំពង់សោម
- វត្ត កោះខ្នុរ ឃុំព្រែករការ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល
- វត្ត មណ្ឌល ឃុំក្អមសំណរ ស្រុកលើកដែក ខេត្តកណ្ដាល
- វត្ត ឧទ្ទេសរារាម ឃុំ ថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
- វត្ត សង្គមមានជ័យ ឃុំលង្វែក ស្រុកកំពង់ត្រាច ខេត្តកំពង់ឆ្នាំង
- វត្ត ជ្រៃមាសសាគរ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល
- វត្ត កេតុបទុម ឃុំតាលុន ស្រុកស្អាង ខេត្តកណ្ដាល
- វត្ត ថ្មដុប ឃុំទទុង ស្រុកដងទង់ ខេត្តកំពត
- វត្ត សូរិយាពោធិមាស ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល
- វត្ត កែប ឃុំ កែប ស្រុកកែប ខេត្តកំពត
- វត្ត ពាមមង្គល ឃុំ រកាកោងទី១ ស្រុក មុខកំពូល ខេត្តកណ្ដាល
- វត្ត អង្គតាឯក ឃុំ ភ្នំតូចឧត្ដុង្គ ស្រុក ឧត្ដុង្គ ខេត្តកំពង់ស្ពឺ
- វត្ត អារញ្ញការាម ឃុំ កំពង់ឆ្នាំង ស្រុក កំពង់ឆ្នាំង  ខេត្តកំពង់ឆ្នាំង
- វត្ត ត្រស់ពិសី ឃុំ អូរតាគី ស្រុក ថ្មគោល ខេត្តបាត់ដំបង
- វត្ត បឹងផ្ដិល ឃុំ ទួលសុភី ស្រុក អូរាំងឪ ខេត្តកំពង់ចាម
- វត្ត គិរីមុនីសាលវ័ន្ត ឃុំ ជើងព្រៃ ស្រុកបាធាយ ខេត្តកពង់ចាម
- វត្ត តាគោក ឃុំ ល្វា ស្រុកព្រះស្ដេច ខេត្តព្រៃវែង
- វត្ត សែនមនោរម្យ ឃុំ ស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី
- វត្ត ចំបក់បិតមាស ឃុំ ពត់ស ស្រុកបាទី ខេត្តតាកែវ
- វត្ត ភ្នំត្រែល ឃុំ ភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត

- វត្ត អម្ពវ័ន ឃុំ ព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្តាល
- វត្ត ពោធិញាណ ឃុំ ព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល
- វត្ត ពោធិសត្ថារាម ឃុំ កំពង់ហៅ ស្រុក កំពង់លែង ខេត្តកំពង់ឆ្នាំង
- វត្ត សោភ័ណារាម ឃុំ ពោធិ៍រំចាក ស្រុក កប្បាស ខេត្តតាកែវ
- វត្ត ពោធិ៍ធម្មរង្សី ឃុំ ថ្នល់បំបែក ស្រុក ចំការលើ ខេត្តកំពង់ចាម
- វត្ត កោះជុំ ឃុំ គយបំបែក ស្រុក ស្វាយរៀង ខេត្តស្វាយរៀង
- វត្ត នាគគួច ឃុំ ក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់
- វត្ត គោកបញ្ចាន់ ឃុំ ចោមចៅ ស្រុកដង្កោ ក្រុងភ្នំពេញ
- វត្ត សេរីសុវណ្ណ ឃុំ រលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
- វត្ត អម្ពររតនារាម ឃុំ កោះអណ្តែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម
- វត្ត ពោធិ៍សាត់ ឃុំ ត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
- វត្ត ថ្មី ឃុំ សង្កែ ស្រុករំដួល ខេត្តស្វាយរៀង
- វត្ត ត្បូងដំរី ឃុំ កំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
- វត្ត គីរីរតនារាម ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី
- វត្ត ស្វាយផ្អែម ឃុំ កន្ទោង ស្រុក អង្គស្នួល ខេត្តកណ្តាល
- វត្ត សាលាឆទាន ឃុំទឹកថ្លា ស្រុក ឫស្សីកែវ ក្រុងភ្នំពេញ
- វត្ត ភ្នំជលាចចា  ស្រុកបាធាយ ខេត្តកំពង់ចាម
- វត្ត ....ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង
- វត្ត សុវណ្ណមាលី ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម
- វត្ត ពួក ឃុំពួក ស្រុកពួក ខេត្តសៀមរាប
- វត្ត ភ្នំបាត់ត្រា ឃុំ ភ្នំត្រងិល ស្រុក ក្រវាញ ខេត្តពោធិ៍សាត់
- វត្ត បន្ទាយទឹក ឃុំ កញ្ជុំ ស្រុកពារាំង ខេត្តព្រៃវែង
- វត្ត ជេតពន ( ត្រី ) ឃុំ ស្តៅ ស្រុកកងមាស ខេត្តកំពង់ចាម
- វត្ត មហារុក្ខារាម ឃុំ រណប ស្រុក សំពៅមាស ខេត្ត ពោធិ៍សាត់
- វត្ត ធម្មរង្សី ឃុំ វាលពន់ ស្រុកខ្លុង ខេត្តកំពង់ស្ពឺ
- វត្ត ប្រាសាទមាស ( ទួលច្រឡឹង ) ឃុំ រលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

ឃ-ការបង្កើតគណៈកម្មាធិការនាយកដឹកនាំការសិក្សាបាន ៤ ខេត្តគឺ :

១-ក្រុងភ្នំពេញ វត្ត **នន្ទមុនី**

២-ខេត្តពោធិសាត់

៣-ខេត្តស្វាយរៀង

៤-ខេត្តតាកែវ ។

ក្រៅពីការផ្សព្វផ្សាយតាមរយៈសៀវភៅ និងការបង្កើតឱ្យមានមណ្ឌលវិបស្សនាធុរៈតាមបណ្ដាខេត្តក្រុងនានា សរុបមាន ១៧ខេត្ត ដែលមានអ្នកប្រតិបត្តិធម៌វិបស្សនាធុរៈប្រមាណជាង ៣ម៉ឺននាក់នោះ ព្រះអង្គបានផ្សព្វផ្សាយតាមរយៈវិទ្យុ ដែលមានពុទ្ធបរិស័ទស្ដាប់ស្ទើរតែពេញផ្ទៃប្រទេសទាំងមូលទៀតផង ។

**៥-សមណៈសក្តិដែលព្រះអង្គទទួលបាន :**

១-ពីឆ្នាំ ១៩៩៦ ត្រូវបានព្រះមហា សុមេធាធិបតី **ទេព វង្ស** តែងតាំងជាអធិបតីមជ្ឈមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅវត្ត **នន្ទមុនី** ក្រុងភ្នំពេញ ។

២-ថ្ងៃទី ០១ ខែមេសា ឆ្នាំ១៩៩៧ ត្រូវបានតែងតាំងឱ្យមានឋានៈជាព្រះធម្មវិបស្សនារាជាគណៈថ្នាក់ **ចត្វា** ។

៣-ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០០០ បានទទួលឋានៈ ជាអធិបតីពុទ្ធមណ្ឌល និង ជាអគ្គនាយកវិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជា ។

៤-ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ ត្រូវបានតែងតាំងឱ្យធ្វើជាព្រះឧបជ្ឈាយ៍ សំរាប់បំបួសកុលបុត្រ ។

ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ អធិបតីពុទ្ធមណ្ឌល និង អគ្គនាយកវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា តាំងពីទទួលបព្វជ្ជា រហូតបានទទួលឋានៈដ៏ខ្ពង់ខ្ពស់នេះ មានការព្យាយាម និងបំពេញតួនាទីរបស់ព្រះអង្គ ដើម្បីដឹកនាំពុទ្ធបរិស័ទឱ្យប្រតិបត្តិនូវសេចក្ដីល្អ ពោលគឺដឹកនាំមហាជនឱ្យធ្វើសេចក្ដីល្អសំរាប់ខ្លួន និង សង្គម ធ្វើចិត្តឱ្យស្ងប់ ប្រាសចាក **លោភៈ ទោសៈ** និង **មោហៈ** ព្រមទាំងធ្វើឱ្យមានបញ្ញាជាក់ច្បាស់ក្នុងសង្ខារទៀតផង ។ ពីមួយថ្ងៃទៅមួយថ្ងៃ តាំងពីព្រលឹមដល់ព្រលប់ ព្រះអង្គមិនដែលមានពេលសំរាកឡើយ ព្រះអង្គដើរតួនាទីស្ថាបនាសង្គម តាមរយៈការផ្សព្វផ្សាយព្រះធម៌ ព្រហ្មចរិយធម៌ដល់ពុទ្ធបរិស័ទស្ទើរតែគ្រប់ទីកន្លែងទាំងអស់ ដោយព្រះទ័យជ្រះថ្លាជាទីបំផុត ។ តែជាអកុសល នៅថ្ងៃទី ៦កើត ខែមាឃ ឆ្នាំមមែ ចត្វាស័ក ព.ស ២៥៤៦ ត្រូវនឹងថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០០៣ វេលាម៉ោង ១:១១នាទីយប់ ព្រះអង្គក៏បានអនិច្ចធម្មក្នុងព្រះជន្មាយុ ៤៧ ព្រះវស្សា ដោយ **កម្មក្ខយមរណៈ** ធ្វើឱ្យពុទ្ធបរិស័ទ សិស្សគណគ្រប់មជ្ឈដ្ឋានទូទាំងព្រះរាជាណាចក្រកម្ពុជា មានក្ដីតក់ស្លុតរន្ធត់អួលអាក់រកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។